ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ៦០

ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១

**សាលដីកា**

លេខៈ ១៦៤

ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៤

# នាមនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២-លោក | ជីវ | កេង | ជាចៅក្រម |
| ៣-លោក | យស់ | សួខឿន | ជាចៅក្រម |
| ៤-លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុនីចរិយា | ជាចៅក្រមរបាយការណ៍ |
| | ក្រឡាបញ្ជី | | |
| អ្នកស្រី | **គួច** | **ចន្ថា** | |
| | តំណាងមហាអយ្យការ | | |
| លោក | **ឈួន** | **ចាន់ថា** | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៩៩"ឆ" ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២៣១ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍រវាង:

ដើមចោទឈ្មោះ **តាំង ហួត** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មុខរបរ ប្រធានផ្នែកធារាសាស្ត្រស្រុកបរិបូរណ៍ មានទីលំនៅបច្ចុប្បន្ន ភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ។

ចុងចំលើយឈ្មោះ **សោម ខេស** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៧៦ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅសព្វថ្ងៃភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ។

**<u>កម្មវត្ថុបណ្តឹង</u>** : ប្តឹងទាមទារដី និងរុះរើសំណង់ចេញពីដីទំនាស់ .

បានឃើញបណ្តឹងសាទុក្ខលេខ ៤៩៩ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ឈ្មោះតាំង ហួត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩៩"ឆ" ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៦០ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែកក្កដាឆ្នាំ១៩៩៥ របស់ភាគីដើមចោទឈ្មោះតាំង ហួត បានបញ្ជាក់ថា : ខ្លួនប្តឹងទាមទារកាន់កាប់ និង គ្រប់គ្រងដីភូមិទំហំ២០៨ ម៉ែត្រការេ ដែលមានទីតាំងស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ពីចុងចម្លើយឈ្មោះសោម ពេស ដែលបានយកដីកម្មសិទ្ធិរបស់ខ្លួន ដោយបានសំអាងហេតុថា ដីទំនាស់នេះខ្លួនបានកាន់កាប់តាំងតែពីឆ្នាំ១៩៨០ រហូតមក ដោយមានដាំដើមដូងចំនួន៤ដើមទៀតផង តែត្រូវងាប់១ដើម នៅរស់៣ដើម រហូតមកទល់ពេលបច្ចុប្បន្ន ។

នៅឆ្នាំ១៩៨៧ ភាគីចុងចោទឈ្មោះ សោម ពេស មកសុំខ្ចីដីទំនាស់ស្នាក់នៅជាបណ្តោះអាសន្ន ដោយបានសន្យាផ្ទាល់មាត់ថានឹងប្រគល់ឱ្យវិញ ហើយក្នុងការស្នាក់នៅជាបណ្តោះអាសន្ននេះ គឺភាគីចុងចោទមានសិទ្ធិត្រឹមត្រូវតែស្នាក់នៅបណ្តោះអាសន្នប៉ុណ្ណោះ រីឯផលដំណាំដែលដុះនៅលើដីទំនាស់ គឺខ្លួនជាអ្នកទទួលរហូតមកទល់ឆ្នាំ១៩៩០ ។ ការខ្ចីស្នាក់នៅនេះ ក៏មានសាក្សីដឹងឮផងដែរ ។ នៅឆ្នាំ១៩៩០ ភាគីចុងចោទបានរារាំងខ្លួនមិនឱ្យប្រមូលផលដំណាំ ហើយមិនតែប៉ុណ្ណោះបានបន្លំយកដីរបស់ខ្លួន មិនព្រមប្រគល់ឱ្យវិញឡើយ ព្រមទាំងបានដាក់ពាក្យសុំកាន់កាប់ដីទំនាស់ទៀតផង ។ ចាប់ពីពេលនោះមក រវាងខ្លួន និងភាគីចុងចោទក៏កើតទំនាស់ ហើយខ្លួនក៏បានដាក់ពាក្យបណ្តឹងទៅរដ្ឋអំណាចមូលដ្ឋានភូមិ និងភូមិបាលស្រុកឱ្យជួយដោះស្រាយ តែពុំមានដំណោះស្រាយឡើយ ក្រោយមកទៀតក៏បានប្តឹងទៅអភិបាលស្រុក តែដោះស្រាយពុំបានសម្រេចឡើយ ។

ក្រោយមកភាគីដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការខេត្តកំពង់ឆ្នាំងនៅក្នុងខែកក្កដាឆ្នាំ១៩៩៥

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះតាំង ហួត ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-សំរេចប្រគល់ដីទំហំ (២០៨ម$^{2}$)ឱ្យទៅឈ្មោះតាំង ហួត គ្រប់គ្រងប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួនចាប់តាំងពីថ្ងៃនេះតទៅ ។

៣-ឱ្យលោក សោម ពេស ព្រមទាំងគ្រួសារញាតិលោហិតចេញផុតពីដីទំនាស់នេះ ក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីថ្ងៃនេះតទៅ សំរេចឱ្យឈ្មោះសោម ពេស បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងហ្វ៊ីងចំនួន១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ និងរង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥០០០៛ បូកសរុប៧.០០០៛ ប្រាក់នេះបានកាត់យកពីដើមចោទដែលបានបង់រួចហើយ បើហួសឧទ្ធរណ៍បង្គាប់ឱ្យលោក សោម ពេស សងប្រាក់ ៧.០០០៛ ទៅឱ្យដើមចោទវិញ និង ឱ្យបង់ពន្ធសមាមាត្រ $\frac{1X\,910.000}{100}$=9100៛ ដោយដាក់ជាប្រយោជន៍នៃថវិការដ្ឋ $\frac{9100 \times 80}{100}$= 7280៛ និង ដាក់ហិបក្រឡាបញ្ជីកាន់ហិបប្រាក់ទូទាំងប្រទេស $\frac{9100 \times 20}{100}$= 1820៛ បើសាលក្រមនេះ ចូលជាស្ថាពរ ។

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ០៧ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា . តាមមាត្រា២,៣ នៃច្បាប់ភូមិបាល .

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី បើភាគិណាមួយមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍ រយៈពេល២ខែ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៤ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៩៦ របស់ឈ្មោះសោម ពេស ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ឆ្នាំង ត្រង់ចំណុចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៩"ឆ"ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៩៦ របស់ឈ្មោះសោម ពេស ជាចុងចំលើយ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៦២ចុះថ្ងៃទី២៩ខែសីហា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ឆ្នាំង ចោលជាអសារបង់ ។

៣-ប្រគល់ដីកើតហេតុទំហំ ២០៨ម² មានព្រំប្រទល់ខាងជើងទល់នឹងដីរបស់ឈ្មោះយាយម៉ៃ ខាងត្បូងទល់នឹងដីរបស់ឈ្មោះយាយ យួន ខាងលិចទល់នឹងដីរបស់ឈ្មោះយាយ ម៉ៃ និងខាងកើតទល់នឹងផ្លូវលំ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ឱ្យទៅឈ្មោះសោម ពេស គ្រប់គ្រងជាកម្មសិទ្ធិ កាលណាសាលដីកានេះ ចូលជាស្ថាពរ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺពន្ធចុះបញ្ជីក្តី និងពន្ធប្តឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និងលើអាជ្ញាធរតុលាការ៥០០០៛ សរុប ១៣.០០០៛ (រៀល) ។ ហើយបង្គាប់ឱ្យឈ្មោះតាំង ហួត សងប្រាក់នេះទៅឱ្យឈ្មោះសោម ពេស វិញ និងបង្គាប់ឱ្យឈ្មោះតាំង ហួត បង់ពន្ធសមាមាត្រមួយភាគរយ(១%) នៃតំលៃដីទំនាស់ កាលណាសាលដីកានេះចូលជាស្ថាពរ ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៥៩ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ឈ្មោះតាំង ហួត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩៩"ឆ" ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ឈ្មោះតាំង ហួត ។

បានឃើញសារណាតបចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះសោម ពេស ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : បណ្តឹងសាទុក្ខរបស់ដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។

សាលដីការជម្រះវេណីលេខ ៩៩"ឆ" ចុះថ្ងៃទី០២-១១-២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសខ្លះ ត្រូវខ្លះ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះតាំង ហួត នាពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលនេះ មកពីសាលាឧទ្ធរណ៍កាត់ក្តីមិនយុត្តិធម៌ ពីព្រោះដីទំនាស់នេះ ជាដីរបស់ខ្លួន បានកាន់កាប់និងដាំដំណាំនៅលើដីនេះ មានដូច ដូង ចំនួន៤ដើម និងដើមទឹកដោះ១ដើម ដើមដូងចាស់មាន៧ដើម និងដូងដាំថ្មីចំនួន៣ដើម ។ ហើយសព្វថ្ងៃ ដូងចាស់នៅសល់១ដើម និងដូងថ្មី៣ សរុបទាំងអស់៤ដើម ។ ខ្លួនសូមលោកប្រធានតុលាការកំពូលមេត្តារកយុត្តិធម៌ឱ្យខ្លួនផង ។

បានស្តាប់ចម្លើយរបស់ឈ្មោះសោម ពេស នាពេលសវនាការថា : ដីទំនាស់នេះ ខ្លួនបានកាន់កាប់និងរស់នៅតាំងពីឆ្នាំ១៩៨០ តាំងពីខ្លួនអត់មានកូន រហូតដល់មានកូន០៤នាក់ ខ្លួនមិនដែលទៅរស់នៅកន្លែងណាផ្សេងទេ គឺរស់នៅលើដីនេះរហូតដល់សព្វថ្ងៃ ។ សូមលោកតុលាការកំពូល មេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះខ្លួនមានដីតែមួយនេះទេ លោកតាំង ហួត គាត់មានដីច្រើនកន្លែង ហើយដីទំនាស់នេះ នៅឆ្ងាយពីលោកតាំង ហួត ចំងាយ ៤០ម ។ ចំពោះដំណាំចាស់មានដើមដូងចំនួន ៦ដើម លោកតាំង ហួត ក៏នេះខ្លួនក៏បេះហូបដែល ហើយខ្លួនដាំដូងនៅលើដីទំនាស់នេះបានចំនួន០៤ដើម ។ខ្លួនសុំសំណូមពរសុំឱ្យតុលាការមេត្តាតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៥៩ ចុះថ្ងៃទី២១-វិច្ឆិកា-២០០០ របស់លោកតាំង ហួត បានធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់ឱ្យទៅភាគីលោក សោម ពេស កាន់កាប់គ្រប់គ្រងទាំងមូលដោយអាងហេតុថា ការអះអាងរបស់លោកតាំងហួតថា' លោកសោម ពេសខ្ចីដីខ្លួនស្នាក់នៅបណ្តោះអាសន្ន ពុំអាចយកជាការបាននោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះ : ការកាន់កាប់រស់នៅរបស់លោកសោម ពេស ធ្វើឡើងដោយព្រលំ ពុំមែនផ្តាច់មុខ ដោយសារលោកតាំង ហួត ក៏បានអាស្រ័យផលលើដំណាំចាស់ និងបានដាំដំណាំថ្មីថែមទៀតលើដីទំនាស់ដែរ ដូចមានរបាយការណ៍របស់ការិយាល័យភូមិបាលស្រុកបរិបូណ៌ និងចម្លើយរបស់លោកសោម ពេស នៅសាលាស្រុកបរិបូណ៌ សុទ្ធតែបញ្ជាក់ថាលោកតាំង ហួត ពិតជាបានដាំដំណាំលើដីទំនាស់មែន ។ហើយសាលាឧទ្ធរណ៍ក៏យល់ឃើញយ៉ាងដូច្នេះដែរ។

ដូច្នេះតាមមាត្រា៦១ និង៦២ នៃច្បាប់ភូមិបាលចាស់ លោកសោម ពេស ពុំអាចមានសិទ្ធិផ្តាច់មុខលើដីទំនាស់បានទេ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៩"ឆ"ចុះថ្ងៃទី០២-វិច្ឆិកា-២០០០របស់សាលាឧទ្ធរណ៍ ដែលបានសំរេចមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៥៩ ចុះថ្ងៃទី២១-វិច្ឆិកា-២០០០ របស់ឈ្មោះតាំង ហួត ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៩៩ "ឆ" ចុះថ្ងៃទី០២-វិច្ឆិកា-២០០០ របស់សាលាឧទ្ធរណ៍ពេញទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៦០ ចុះថ្ងៃទី២៦-កុម្ភៈ-២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីធ្វើការជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកតាំង ហួត បានបង់នៅតុលាការកំពូលចំនួន១៩.០០០៛ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យលោក សោម ពេស សងប្រាក់ ១៩.០០០៛ ទៅលោកតាំង ហួត វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០០៤ ។